# ការធ្វើតាមព្រះយេស៊ូវ នៅប្រទេសអេស្តូនី

ជួបជាមួយនឹងហ៊ូហ្គោ

ហ៊ូហ្គោធ្វើតាមព្រះយេស៊ូវ ដោយការអធិស្ឋានពេលគាត់ត្រូវការជំនួយ ។ គាត់ធ្លាប់មានសុបិនអាក្រក់ ។ គាត់បានអធិស្ឋានដើម្បីទទួលការលួងលោម ។ គាត់និយាយថា « ព្រះយេស៊ូវបានជួយខ្ញុំ » ។

ហ៊ូហ្គោក៏ធ្វើតាមព្រះយេស៊ូវដោយការចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់គាត់ផងដែរ ។ គាត់ចូលចិត្តបង្រៀនពួកគេអំពីអ្វីដែលគាត់រៀននៅឯព្រះវិហារ ។ គាត់ប្រាប់ពួកគេថាមនុស្សគ្រប់គ្នាជាកូនរបស់ព្រះ ។ គាត់និយាយថា « ខ្ញុំអញ្ជើញពួកគេទៅព្រះវិហារ និងសកម្មភាពទាំងឡាយ » ។ « វាធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អ » ។





## អំពី ហ៊ូហ្គោ



អាយុ ៖ ៩ ឆ្នាំ

មកពី ៖ ប្រទេសអេស្តូនី

ភាសា ៖ ភាសាអេស្តូនី ភាសាអង់គ្លេស

គោលដៅ ៖

១) លេងព្យាណូឲ្យបានល្អជាងមុន

២) រស់នៅជានិរន្តរ៍ជាមួយគ្រួសាររបស់គាត់ទាំងមូល រួមទាំងជីដូនជីតារបស់គាត់ផងដែរ ។

ចំណង់ចំណូលចិត្ត ៖

- ការច្រៀងនៅក្នុងក្រុមចម្រៀងអូប៉េរ៉ាថ្នាក់ជាតិអេស្តូនីសម្រាប់កុមារ
- ការលេងព្យាណូ
- ការសម្តែងល្ខោន
- កីឡាបាល់ទាត់

គ្រួសារ ៖ ម៉ាក់ បងស្រី បងប្រុសពីរនាក់ និងឆ្កែឈ្មោះថា អាយឡា



## អ្វីដែលហ៊ូហ្គោចូលចិត្ត

ព្រះគម្ពីរ ៖ នីហ្វៃទី១ ៣:៧

ប្រពៃណីក្នុងគ្រួសារ ៖ ការគូរគំនូរ និងការលាក់ស៊ុតនៅថ្ងៃបុណ្យអ៊ីស្ទើរ

ផ្លែឈើ ៖ ស្វាយ

ពណ៌ ៖ ទឹកក្រូច

ចម្រៀងកុមារ ៖ « ការអធិស្ឋានរបស់កុមារ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ ៦ ) ។









## អ្នកក៏អាចធ្វើតាមព្រះយេស៊ូវបានដែរ !

មានវិធីជាច្រើនដើម្បីធ្វើតាមព្រះយេស៊ូវ ។ សូមសរសេរ និងប្រាប់យើងអំពីពេលមួយដែលប្អូនបានធ្វើតាមទ្រង់ !

